**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

*ថ្ងៃ ពុធ ១ កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*
*រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
## ពិធី
## "ប្រកាសពង្រីកការប្រើប្រាស់មុខងាររបស់ប្រព័ន្ធ FMIS, ការអនុវត្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុង, ការប្រើប្រាស់ប្រព័ន្ធ FMIS Portal ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការដាក់ឱ្យអនុវត្តគម្រោងរៀបចំមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រសួងចំនួន ៥"

នារសៀលថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០២៣, នៅសាលាជាតិគយ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំពិធី "**ប្រកាសពង្រីកការប្រើប្រាស់មុខងាររបស់ប្រព័ន្ធ** FMIS, **ការអនុវត្តនីតិវិធីតាមប្រព័ន្ធ** FMIS **ទាំងស្រុង, ការប្រើប្រាស់ប្រព័ន្ធ** FMIS Portal **ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការដាក់ឱ្យអនុវត្តគម្រោងរៀបចំមុខងារ គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រសួងចំនួន ៥**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង-ស្ថាប័នទាំងអស់, រដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក និង ឃុំ-សង្កាត់ រួមជាមួយតំណាងដៃគូអភិវឌ្ឍ ទាំងនៅកន្លែងប្រារព្ធពិធីផ្ទាល់ និង តាមប្រព័ន្ធវីដេអូអនឡាញប្រមាណ ១ ៤០០ នាក់ ។

ប្រព័ន្ធ Financial Management Information Systerm (FMIS) គឺជាឧបករណ៍ស្នូលដែលមិនអាចខ្វះបានសម្រាប់ជួយគាំទ្រ និង ជំរុញដល់ការសម្រេចបាននូវគោលដៅ នៃដំណាក់កាលនីមួយៗរបស់កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ រួមមាន ការបង្កើនភាពជឿទុកចិត្តនៃថវិកា, ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ, ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និង ការបង្កើនគណនេយ្យភាព សមិទ្ធកម្ម ព្រមទាំង ជួយបង្កើនប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ សមិទ្ធផលជាច្រើនបានកើតចេញពីការអនុវត្តគម្រោង FMIS តាំងពីជំហានទី ១ ក្នុងឆ្នាំ ២០១៤ រហូតមកដល់បច្ចុប្បន្ននេះ ដែលជាជំហានទី ៣ គឺមិនមែនកើតចេញដោយភ្លាមៗ និង ងាយៗនោះទេ គឺកើតចេញពីការប្តេជ្ញាចិត្តខ្ពស់ និង កិច្ចខិតខំប្រឹងប្រែងយ៉ាងមោះមុត មិនរាថយ របស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស ក្រុមការងារគ្រប់គ្រងគម្រោង FMIS និង ការចូលរួមគាំទ្រយ៉ាងសស្រាក់សស្រាំពីតួអង្គដែលមានការពាក់ព័ន្ធនៅតាមក្រសួង-ស្ថាប័ន ស្របតាមឆន្ទៈនយោបាយ និង ការតម្រង់ទិសយ៉ាងម៉ឺងម៉ាត់ និង ឈ្លាសវៃបំផុត

របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាអគ្គមគ្គុទេសក៍ដ៏ឆ្នើមរបស់កម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានប្រកាសការដាក់ឱ្យអនុវត្ត និង ប្រើប្រាស់ជាផ្លូវការ÷

១). នីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញាតាមប្រព័ន្ធ FMIS ទាំង ស្រុងសម្រាប់ក្រសួង-ស្ថាប័នចំនួន ៥ បន្ថែម,

២). នីតិវិធីចំណាយថវិកាទូទាត់សេវាបំណុលក្នុងជំពូក ៥០ និង ៦៦ តាមប្រព័ន្ធ FMIS ទាំងស្រុង នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ,

៣). ប្រព័ន្ធ FMIS Portal ជំនាន់ទី១ ទៅកាន់រដ្ឋបាលក្រុង ស្រុក និង ឃុំ-សង្កាត់ សរុបចំនួន ៥៤២ បន្ថែម,

៤). មុខងារស្នូល នៃប្រព័ន្ធ FMIS ទៅកាន់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ បន្ថែមថ្មី,

៥). មុខងាររៀបចំផែនការថវិកា ទៅកាន់ក្រសួង-ស្ថាប័នចំនួន ១២ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញថ្នាក់កណ្តាលចំនួន ១៧ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង ២៥,

៦). មុខងារលទ្ធកម្មពេញលេញ ទៅកាន់អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាលចំនួន ២០ និង មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង ២៥

៧). គម្រោង "**មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ**" នៅក្នុងប្រព័ន្ធ FMIS ជាមួយក្រសួង-ស្ថាប័នចំនួន ៥ គឺ ១. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២. ក្រសួងបរិស្ថាន ៣. ក្រសួងសុខាភិបាល ៤. ក្រសួងមហាផ្ទៃ និង ៥. ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, និង

៨). នីតិវិធីចំណាយថវិកាចរន្តគ្រប់មុខសញ្ញាតាមប្រព័ន្ធ FMIS ទាំងស្រុងសម្រាប់ក្រសួងយុត្តិធម៌នៅក្នុងខែ មិថុនា ២០២៣ តទៅ ។

ជាមួយនឹងការថ្លែងអំណរគុណចំពោះលទ្ធផលការងារដែលសម្រេចបានរបស់ **ក្រុមការងារគ្រប់គ្រងគម្រោង FMIS** ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហ៊ាន សាហ៊ីប** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ក៏ដូចជាការវាយតម្លៃខ្ពស់ចំពោះការចូលរួមចំណែករបស់តំណាងដៃគូអភិវឌ្ឍ, អគ្គនាយកដ្ឋាន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានគាំទ្រ និងចូលរួមសហការជាកម្លាំងរួមក្នុងការកសាងសម្រេចបាននូវសមិទ្ធផលជាច្រើនកន្លងមក, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ក៏បានរម្លឹកនូវឱវាទានុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលតែងដាស់តឿនបុគ្គលិកមន្ត្រីរាជការទាំងអស់ថា ÷ "**កែទម្រង់គឺរស់ មិនកែទម្រង់គឺស្លាប់**" និង "**គ្មានលទ្ធផលណាដែលបានមកដោយមិនមានការបង់ថ្លៃនោះទេ ហើយក៏គ្មានការកែទម្រង់ណាដែលសម្រេចបានដោយមិនមានការលះបង់នោះដែរ**" ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានលើកទឹកចិត្ត និងជំរុញថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់ ដែលមានតួនាទីភារកិច្ចក្នុងកិច្ចការថវិកា និងហិរញ្ញវត្ថុ ឱ្យលះបង់ប្រយោជន៍ស្វនត្ត ប្តេជ្ញាឱ្យបានមុតមាំ តាមគំរូលះបង់ប្រកបដោយវីរភាពដ៏អង់អាចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** ដែលតែងតែតម្កល់ប្រយោជន៍ជាតិជាធំ និងសូមផ្លាស់ប្តូរផ្នត់គំនិតទទួលយកនូវបរិការណ៍នៃការផ្លាស់ប្តូររបៀបរបបបំពេញការងារថ្មី ខិតខំបំពេញភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ប្រកបដោយវិជ្ជាជីវៈ ដោយគិតជាធំទៅលើប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាតិ និងតម្លៃនៃលុយ ដើម្បីការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង ៕